ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គស្នងការដ្ឋាននគរបាលជាតិ
នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌
នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស
និងការពារអនីតិជន
ការិយាល័យប្រឆាំងការជួញដូរមនុស្សឆ្លងដែន

# របាយការណ៍សរុបស្តីពីអំពើជួញដូរមនុស្សទៅប្រទេសចិនឆ្នាំ២០១៧

## I-សភាពការណ៍:

អំពើជួញដូរមនុស្ស មិនមែនកើតមានតែនៅក្នុងប្រទេសណាមួយនោះទេ វាជាបញ្ហាសកល ដែលជនចំណាកស្រុកត្រូវបានគេចរាចរពីប្រទេសមួយទៅប្រទេសមួយក្នុងតំបន់ អាស្រ័យទៅតាមការប្រែប្រួលនៃសេដ្ឋកិច្ច និងតម្រូវការរបស់មនុស្ស។ ដោយឡែកនៅកម្ពុជា លំហូរនៃជនចំណាកស្រុកនៅតែកើតមាន ដែលមិនទាន់អាចទប់ស្កាត់បាន មូលហេតុដោយសារបញ្ហាធំៗពីរគឺ កត្តាទាក់ទាញពីក្រៅប្រទេស និងកត្តាជម្រុញពីក្នុងប្រទេស ដែលធ្វើឲ្យកម្ពុជានៅតែជាប្រទេសប្រភព ឆ្លងកាត់ និងគោលដៅនៃអំពើជួញដូរមនុស្ស ជនល្មើសបានប្រើប្រាស់ល្បិចកល និងផ្លាស់ប្តូររូបភាពនៃសកម្មភាពថ្មីៗជាបន្តបន្ទាប់ ដើម្បីអូសទាញមនុស្ស និងទប់ទល់ជាមួយការស្រាវជ្រាវរបស់សមត្ថកិច្ច ជាក់ស្តែងដូចជាការជួញដូរស្ត្រីខ្មែរនាំយកទៅប្រទេសចិន បង្ខំឲ្យយកប្តីជនជាតិចិនផ្ទុយពីឆន្ទៈ ត្រូវបានគេឃោសនាបោកបញ្ឆោតថា នាំទៅធ្វើការនៅប្រទេសផ្សេងៗ ឬប្រទេសចិនទទួលបានប្រាក់ឈ្នួលខ្ពស់ ឬយកប្តីជនជាតិចិនសុទ្ធតែជាអ្នកមានជីវភាពធូរធា ឲ្យប្រាក់ឧបត្ថម្ភរហូតដល់៥០០០$ នាំយកចេញដោយមានឬគ្មានលិខិតឆ្លងដែន គ្មានទិដ្ឋាការ ឬប្រើប្រាស់លិខិតឆ្លងដែនអ្នកដទៃ ដែលមានកិនភាគប្រហាក់ប្រហែល ធ្វើដំណើរតាមផ្លូវគោក តាមច្រករបៀងឆ្លងកាត់តាមប្រទេសវៀតណាមចូលប្រទេសចិនដោយខុសច្បាប់។

## II-អំពើជួញដូរមនុស្សឆ្លងដែនក្រោមរូបភាពអាពាហ៍ពិពាហ៍:

### ១/អាពាហ៍ពិពាហ៍ស្របច្បាប់:

ក្នុងឆ្នាំ២០១៧ ជនបរទេសដែលបានមកដាក់ពាក្យសុំរៀបការជាមួយពលរដ្ឋខ្មែរសរុបចំនួន១៥៥៩នាក់ មាន៤៣សញ្ជាតិ ក្នុងនោះច្រើនជាងគេមាន កូរ៉េ៥៤១នាក់ អាមេរិក៤១០នាក់ និងចិន ១៨០នាក់ និងបានវាយតម្លៃបញ្ជូនឯកសារឲ្យក្រុមការងារចម្រុះច្រកចេញ-ចូលតែមួយសរុបចំនួន១៤៩២ឯកសារ ទន្ទឹមនេះបានរកឃើញបាតុភាពមួយចំនួនៈ

-នារីខ្មែរក្រោយពេលរៀបការនិងបានចូលសញ្ជាតិកូរ៉េហើយបានលែងលះចំនួន៦៦នាក់ បានមកដាក់ពាក្យសុំរៀបការលើកទី២ជាមួយបុរសខ្មែរ

-បុរសជនជាតិកូរ៉េចំនួន៦នាក់ បានមកដាក់ពាក្យសុំរៀបការជាមួយនារីខ្មែរចំនួន២លើក ដោយមានឯកសារលែងលះ តាមការបំភ្លឺអាណាព្យាបាលនៅកម្ពុជារបស់នារីទី១បានឲ្យដឹងថាមូលហេតុរស់នៅមិនចុះសម្រុងគ្នា។

-ប្តីប្រពន្ធជនជាតិខ្មែរនិងកូរ៉េចំនួន២គូ បានមកដាក់ពាក្យសុំរៀបការឡើងវិញ ដើម្បីបំពេញបែបបទឲ្យបានត្រឹមត្រូវ តាមឯកសារអត្រានុកូលដ្ឋានរបស់សាម៉ីខ្លួនពលរដ្ឋខ្មែរ មូលហេតុកាលពីឆ្នាំ២០០៧ រៀបការលើកទី១ សាម៉ីខ្លួនប្រើឯកសាររបស់បងប្អូនត្រូវបានអាជ្ញាធរកូរ៉េរកឃើញ និងតម្រូវឲ្យលែងលះគ្នា ដើម្បីឲ្យបំពេញបែបបទត្រឹមត្រូវឡើងវិញ។

-សំណុំឯកសារលេខ៣១៦៣ របស់ឈ្មោះ Meach Sok Chea ភេទប្រុស សញ្ជាតិខ្មែរ-បារាំង និងពលរដ្ឋខ្មែរឈ្មោះ ចិន្តា ស្រីលាក់ ខុសស្នាមមេដៃសាម៉ីខ្លួនខាងប្រុស កំពុងស្រាវជ្រាវ។

**ការសន្និដ្ឋានៈ**

ទោះបីជាពុំទាន់មានព័ត៌មាន ឬភស្តុតាងគ្រប់គ្រាន់ ដើម្បីកំណត់ឲ្យបាននូវបទល្មើសក៏ដោយ ក៏អាចនឹងមានការយកអាពាហ៍ពិពាហ៍ស្របច្បាប់ធ្វើជាស្ពាន ដើម្បីបានបំពេញបែបបទស្របច្បាប់ នាំយកពលរដ្ឋខ្មែរចេញទៅក្រៅប្រទេសក្នុងគោលបំណងទុច្ចរិត ដោយមូលហេតុរដ្ឋាភិបាលពុំទាន់មានយន្តការផ្លូវការ ដើម្បីតាមដានពីសុខទុក្ខឬសកម្មភាពរស់នៅជាក់ស្តែងនៅក្រៅប្រទេសក្រោយពេលរៀបការ។

**២/អាពាហ៍ពិពាហ៍មិនអនុវត្តតាមអនុក្រឹត្យ១៨៣ អ.ន.ក្រ.ប.ក ចុះថ្ងៃទី០៣/១១/២០១៨**

ទេសន្តប្រវេសន៍ជាស្រីខ្មែរវ័យក្មេងជាច្រើនរូប ត្រូវបានគេនាំយកចេញទៅប្រទេសចិន លក់ឲ្យបុរសជនជាតិចិន បង្ខំឲ្យយកប្តីឬរៀបការផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះដោយមូលហេតុៈ

**ក-កត្តាជម្រុញពីក្នុងប្រទេសៈ**

+គ្មានចំណេះដឹង ឆាប់ជឿតាមគេ

+ភាពក្រីក្រ

+ខ្វះខាតការងារធ្វើក្នុងប្រទេស

+មិនមានបំណងចង់ធ្វើការក្នុងប្រទេស ចង់ឃើញភាពទាន់សម័យ ចង់ស្គាល់ប្រទេសគេ ដែលមានលក្ខណរស់នៅស្រួលជាងក្នុងស្រុក និងមិនចាំបាច់ចំណាយលុយអាចទៅបរទេសបាន

+ការផ្លាស់ប្តូរផ្នត់គំនិត ប្រពៃណី និងបទដ្ឋានរស់នៅកាន់តែជឿនលឿន

+ឃើញគេទៅមានអនាគតល្អ

**ខ-កត្តាទាក់ទាញពីក្រៅប្រទេសៈ**

+មេខ្យល់ឃោសនាអូសទាញ

+មិនបាច់ចំណាយលុយ

+មេខ្យល់ឲ្យប្រាក់ឧបត្ថម្ភច្រើន

+តម្រូវការស្ត្រី និងចង់បានកូនពីប្រទេសចិន

+មិនតម្រូវការបែបបទច្រើន អាចចុះលិខិតអាពាហ៍ពិពាហ៍នៅចិនបាន

**គ-ល្បិចកលអូសទាញនិងដឹកជញ្ជូនៈ**

+បោកបញ្ឆោតថា នាំទៅធ្វើការនៅប្រទេសផ្សេងៗ ឬប្រទេសចិន បានប្រាក់ច្រើន ឬរៀបការជាមួយបុរសជនជាតិចិនសុទ្ធតែជាអ្នកមានជីវភាពធូរធារ

+ចេញសោហ៊ុយឲ្យទាំងអស់ ព្រមទាំងឲ្យថ្លៃទឹកដោះពី៣០០$ទៅ១៥០០$ និងបច្ចុប្បន្នបង្កើនដល់៥០០០$

+ទាក់ទងតាមទូរស័ព្ទ ណាត់ជួបគ្នានៅកន្លែងណាមួយ ឲ្យសាម៉ីខ្លួនជិះយន្តហោះឬរថយន្តទៅម្នាក់ឯង ក្រោមការចង្អុលណែនាំ និងជួយសម្របសម្រួលជាមួយសមត្ថកិច្ចពីមេខ្យល់

+នាំយកចេញតាមផ្លូវគោក ឆ្លងកាត់តាមច្រករបៀង ចូលប្រទេសវៀតណាម និងចូលទៅប្រទេសចិន

+នាំយកចេញដោយប្រើលិខិតឆ្លងដែនគ្មានទិដ្ឋាការ ឬប្រើលិខិតឆ្លងដែនអ្នកដទៃដែលមានភិនភាគប្រហាក់ប្រហែល

+នាំយកចេញដោយគ្មានលិខិតស្នាមទាំងអស់

+ចាត់បណ្តាញចាំទទួល និងបញ្ជូនជាដំណាក់ៗរហូតដល់ប្រទេសចិន និងគ្រប់គ្រងចាត់ចែងឲ្យរកប្តីជនជាតិចិន។

+នាំទៅចុះលិខិតអាពាហ៍ពិពាហ៍ ដោយមិនរៀបការ ក្រោមការរៀបចំសម្របសម្រួលបែបបទពីមេខ្យល់

**-ការរងគ្រោះនៅប្រទេសចិនៈ**

+បង្ខំឲ្យយកបុរសជនជាតិចិនធ្វើជាប្តីដោយមិនរៀបការ

+បម្រើគេក្នុងគ្រួសារនិងជាទាសករផ្លូវភេទដើម្បីយកតែកូន
+ដកហូតលិខិតឆ្លងដែន បិទសិទ្ធិសេរីភាព
+គ្មានសិទ្ធិកាន់កាប់លុយដែលរកបាន
+ស្នាក់នៅមិនស្របច្បាប់ ត្រូវនគរបាលចាប់ខ្លួន
+ចង់វិលមកកម្ពុជាវិញ ត្រូវលួចរត់ និងគ្មានលុយទិញសំបុត្រយន្តហោះ។

**-កិច្ចសហការៈ**

+សហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
+សហការជាមួយស្ថានទូត ស្ថានតំណាងកម្ពុជានៅប្រទេសចិន ស្ថានទូតកម្ពុជានៅហូជីមិញ និង ហាណូយ
+អង្គការ IOM, AIM SWAT, ចាប់ដៃ, អាដហុក, CWCC, LSCW, IJM និងមណ្ឌលរតនៈ
+សហការជាមួយស្នងការដ្ឋាននគរបាល២៥រាជធានី-ខេត្ត

**-ការសង្គ្រោះនិងបញ្ជូនត្រឡប់មកវិញៈ**

បានសហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ស្ថានទូត ស្ថានកុងស៊ុលខ្មែរនៅចិននិងនៅវៀតណាម និងអង្គការចាប់ដៃ, AIMSWAT, IOM, IJM, LSCW, ADHOC, CWCC និងមណ្ឌលរតនៈបានអន្តរាគមន៍ និងសង្គ្រោះជនរងគ្រោះត្រូវគេជួញដូរទៅប្រទេសចិនបញ្ជូនត្រឡប់មកកម្ពុជាវិញ សរុបចំនួន៥៨នាក់ ស្រីក្នុងនោះបញ្ជូនមកពីប្រទេសចិនចំនួន៤៥នាក់និងពីប្រទេសវៀតណាម ចំនួន១៣នាក់។

**III-ការទទួលពាក្យបណ្តឹងពាក់ព័ន្ធអំពើជួញដូរទៅប្រទេសចិនៈ**

បានទទួលពាក្យបណ្តឹងសរុបចំនួន៤៥បណ្តឹង ក្នុងនោះមានៈ
+បណ្តឹងទាមទារយកកូនត្រឡប់ពីប្រទេសចិនមកកម្ពុជាវិញចំនួន១០បណ្តឹង
+បណ្តឹងទាមទារចាត់ការមេខ្យល់តាមច្បាប់ចំនួន៣៥បណ្តឹង

**-លទ្ធផលស្រាវជ្រាវនិងបង្រ្កាបៈ**

ក្នុងឆ្នាំ២០១៧ មានជនរងគ្រោះដោយការជួញដូរស្ត្រីខ្មែរទៅប្រទេសចិនសរុបចំនួន១០៣នាក់ ក្នុងនោះមានចំណាត់ការដូចខាងក្រោមៈ

+ស្រាវជ្រាវ និងបង្រ្កាបចំនួន១១ករណី ឃាត់ខ្លួនជនសង្ស័យចំនួន១៦នាក់ ស្រី១២នាក់ សង្គ្រោះជនរងគ្រោះចំនួន២៦នាក់ស្រី បញ្ជូនឲ្យគ្រួសារចំនួន២៦នាក់ ក្នុងនោះសហការជាមួយស្ថានទូតខ្មែរនិងសមត្ថកិច្ចនៅវៀតណាម ឃាត់ខ្លួនជនសង្ស័យនៅវៀតណាម ចំនួន០២នាក់ បញ្ជូនជនរងគ្រោះមកកម្ពុជាវិញចំនួន១៣នាក់
+បញ្ជូនសំណុំរឿងទៅស្នងការដ្ឋាននគរបាលរាជធានី-ខេត្តចំនួន០៣ករណី
+កំពុងស្រាវជ្រាវចំនួន៨៩ករណី
+ចាប់តាមដីកា១នាក់ឈ្មោះ Liu Wing Hing សញ្ជាតិចិន កាលពីថ្ងៃទី២៥/១២/២០១៧ ឃុំខ្លួនតាមដីកាលេខ៧១០(ដ)ដ.ច.ន. ចុះថ្ងៃទី២៧/១២/២០១៧ ពីបទការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន (មាត្រា១១) ផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេល០៧ឆ្នាំ ដោយមូលហេតុកាលពីឆ្នាំ២០១៦មានឈ្មោះ អ៊ិន ស៊ីម៉ាណាន់ ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ បានបង្កើតអង្គការមួយឈ្មោះថា IPAT មានទីតាំងនៅខណ្ឌមានជ័យ រាជធានីភ្នំពេញ ហើយបានឃោសនា បោកប្រាស់ និងជ្រើសរើសពលរដ្ឋបាន២៤នាក់ បង់ប្រាក់ក្នុងម្នាក់ៗ២៥០០$ ដើម្បីនាំយកទៅឲ្យរៀនផ្នែម៉ូតសំលៀកបំពាក់ នៅសកលវិទ្យាល័យយានតាយណានសាន ប្រទេសចិន ដោយបានសហការជាមួយជនជាតិចិនឈ្មោះ Liu Wing Hing ហៅ សាយមិន ជាអ្នកទាក់ទងជាមួយសាលានៅប្រទេសចិន។ ឈ្មោះ អ៊ិន ស៊ីម៉ាណាន់ បានបញ្ជូនពលករទាំង២៤នាក់ទៅប្រទេសចិន ដោយមិនមានការ

អនុញ្ញាតពីក្រសួងការងារ ឲ្យធ្វើជាកម្មកររោងចក្រឈ្មោះ ណានសាន ក្នុងខេត្តសានតុង នៅទីនោះត្រូវបានគេបង្ខំឲ្យធ្វើការគ្មានថ្ងៃឈប់សម្រាក បានប្រាក់ឈ្នួលតិចតួច។

IV-**បទពិសោធន៍:**

**-ចំណុចខ្លាំង:**

+ការស្រាវជ្រាវ និងបង្ក្រាបក្នុងឆ្នាំ២០១៧ បើប្រៀបធៀបទៅនឹងឆ្នាំ២០១៦មាន១១/៧ កើនឡើង ៤ករណី ស្មើ៥៧,១៤%។

+សហការល្អជាមួយក្រសួងការបរទេស ស្ថានទូត ស្ថានតំណាងក្រៅប្រទេស អង្គការពាក់ព័ន្ធ និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត

+ជនរងគ្រោះ និងក្រុមគ្រួសារ ចូលរួមផ្តល់ព័ត៌មាន និងសហការល្អ

+មានការសម្របសម្រួល និងសហការល្អពីស្ថាប័នអយ្យការ និងតុលាការ

+មន្ត្រីអនុវត្តច្បាប់មានស្មារតីតស៊ូ និងទទួលខុសត្រូវ ក្នុងការស្រាវជ្រាវ និងបង្ក្រាបបទល្មើស។

**-ចំណុចខ្សោយ:**

+ការយល់ដឹងពីច្បាប់ នីតិវិធី និងសមត្ថភាពជំនាញរបស់មន្ត្រីអនុវត្តច្បាប់នៅមានកម្រិត

+ការស្រាវជ្រាវស្វែងរកសាក្សី និងភស្តុតាង ដើម្បីដាក់បន្ទុកលើជនសង្ស័យមិនទាន់លំអិត និងរឹងមាំ

+ខ្វះសម្ភារៈ ឧបករណ៍ សម្រាប់បម្រើឲ្យការងារជំនាញ

+ការស្រាវជ្រាវស៊ើបអង្កេត និងសង្គ្រោះជនរងគ្រោះយឺតយ៉ាវ មូលហេតុរឿងច្រើនតែបរិមាណនិងធនធានមនុស្សមានតិច។

**-បញ្ហាប្រឈម:**

+កិច្ចសហការរបស់ស្នងការដ្ឋាននគរបាលរាជធានី-ខេត្តមួយចំនួន ជាមួយនាយកដ្ឋានមិនទាន់ធ្វើបានល្អ

+ខ្វះបរិមាណ និងធនធានមនុស្ស ជាពិសេសនគរបាលជាស្ត្រី ដើម្បីសម្ភាសន៍ជនរងគ្រោះជាស្ត្រី

+ខ្វះការចូលរួមសហការពីគ្រួសារ និងជនរងគ្រោះ

+ជនរងគ្រោះមកប្តឹង ដោយគ្មានភស្តុតាងមកបញ្ជាក់ និងគ្មានអត្តសញ្ញាណជនសង្ស័យ

+ខ្វះយន្តការទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ ជំនួយឲ្យគ្នាទៅវិញទៅមក ផ្នែកច្បាប់ ជាមួយប្រទេសចិន និងវៀតណាម ជាពិសេសការប្រមូលភស្តុតាងពីក្រៅប្រទេស

+មិនទាន់មានយន្តការតាមដានសុខទុក្ខ និងស្រាវជ្រាវពលរដ្ឋខ្មែរ ក្រោយពេលរៀបការ ហើយទៅរស់នៅក្រៅប្រទេស

+ច្រកចេញ-ចូលតាមព្រំដែនច្រើន ងាយស្រួល និងមានការឃុបឃិតគ្នាជាមួយសមត្ថកិច្ចប្រចាំនៅទីនោះ

+ការស្រាវជ្រាវ ប្រមូលភស្តុតាង តាមបណ្តាញទំនាក់ទំនងសង្គម ឬការប្រើប្រាស់បច្ចេកវិទ្យាទំនើប ដូចជា កាមេរ៉ាសុវត្ថិភាព នៅមានកម្រិតនៅឡើយ

+មុខសញ្ញាមេខ្យល់នៅក្នុងស្រុកមួយចំនួនជាអាណាព្យាបាលរបស់ស្ត្រីខ្មែរ ដែលធ្លាប់បានរៀបការកូន ហើយទៅរស់នៅប្រទេសចិន

V-**វិធានការទប់ស្កាត់:**

+ផ្សព្វផ្សាយអប់រំតាមប្រព័ន្ធឃោសនានានាដូចជា ទូរទស្សន៍, វិទ្យុ, សារព័ត៌មាន និងភូមិ-ឃុំមានសុវត្ថិភាព

+ផ្សព្វផ្សាយ និងពង្រឹងដល់សមត្ថកិច្ចតាមព្រំដែន ឬអាកាសយានដ្ឋាន ឲ្យរឹតបន្តឹងការចេញទៅប្រទេសចិន ចំពោះស្ត្រីវ័យក្មេង ដែលបន្លំខ្លួនជាអ្នកទេសចរណ៍

+ផ្សព្វផ្សាយដល់អាជ្ញាធរឃុំ-សង្កាត់ ឲ្យរឹតបន្តឹងការចេញលិខិតបញ្ជាក់នៅលីវ ចំពោះស្ត្រីវ័យក្មេង និងបញ្ជាក់ឲ្យច្បាស់យកទៅប្រើប្រាស់ក្នុងគោលបំណងអ្វីនៅទីណា
+បង្កើនការស្រាវជ្រាវ បង្ក្រាបមេខ្យល់ និងបណ្ដាយជួញដូរមនុស្សឆ្លងដែន។

VI-**ការងារបង្កើនសមត្ថភាព**

+បង្កើនការបណ្ដុះបណ្ដាលច្បាប់ នីតិវិធី ការស៊ើបអង្កេតប្រមូលភស្តុតាង ដើម្បីបង្កើនសមត្ថភាពមន្ត្រីអនុវត្តច្បាប់
+ពង្រឹងការគ្រប់គ្រងទូរស័ព្ទទាន់ហេតុការណ៍ និងសហការជាមួយវិទ្យុABC ដើម្បីទទួលពាក្យបណ្ដឹង និងសំណូមពររបស់ប្រជាជនរហ័ស
+បង្កើនការសហការជាមួយអង្គការពាក់ព័ន្ធ ដើម្បីប្រមូលព័ត៌មាន និងសង្គ្រោះទាន់ពេល
+បង្កើនការសហការជាមួយក្រសួងការបរទេស និងស្ថានទូតខ្មែរនៅប្រទេសចិន វៀតណាម ដើម្បីសង្គ្រោះបានទាន់ពេល

VII- **ទិសដៅ**

+បន្តសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេស ដែលបានមកដាក់ពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍ និងពិនិត្យសំណុំឯកសារស្រាវជ្រាវប្រមូលព័ត៌មាន សំដៅរកឲ្យឃើញអាពាហ៍ពិពាហ៍ក្លែងក្លាយពាក់-ព័ន្ធបទល្មើសជួញដូរមនុស្ស
+ជម្រុញការងារបង្ការ-ទប់ស្កាត់ និងស្រាវជ្រាវបង្ក្រាប តាមរយៈការចុះផ្សព្វផ្សាយ និងណែនាំដោយផ្ទាល់ដល់ស្នងការដ្ឋាននគរបាល២៥រាជធានី-ខេត្ត អំពីសកម្មភាព ឃោសនា លួងលោម បោកបញ្ឆោត ដើម្បីជ្រើសរើស និងនាំយកនារីវ័យក្មេងទៅលក់ឲ្យបុរសជនជាតិចិនធ្វើជាប្រពន្ធ ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ
+បន្តសហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ស្ថានទូតខ្មែរនៅចិននិងវៀតណាម និងអង្គការដៃគូ ដើម្បីប្រមូលព័ត៌មាន និងសង្គ្រោះបានទាន់ពេលវេលា
+បង្កើនការស្រាវជ្រាវ បង្ក្រាបមេខ្យល់ និងបណ្ដាញជួញដូរមនុស្សឆ្លងដែន
+បន្តទំនាក់ទំនងសួរសុខទុក្ខតាមទូរស័ព្ទ ជាមួយពលរដ្ឋខ្មែរ ដែលបានទៅរស់នៅបរទេស ក្រោយពេលរៀបការ ដើម្បីតាមដានពីសុខទុក្ខ និងជួយសង្គ្រោះ

VIII- **សំណូមពរ:**

+ស្នើសុំឲ្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ណែនាំឲ្យស្ថានទូតខ្មែរប្រចាំនៅប្រទេសចិន ឲ្យរឹតបន្តឹងការបញ្ជាក់ទទួលស្គាល់លើលិខិតនៅលីវរបស់នារីវ័យក្មេង ដើម្បីយកទៅបំពេញបែបបទចុះលិខិតអាពាហ៍ពិពាហ៍នៅអាជ្ញាធរប្រទេសចិន ដើម្បីរកឃើញមេខ្យល់ជួញដូរមនុស្ស និងដើម្បីចូលរួមក្នុងការងារបង្ការ-ទប់ស្កាត់
+ស្នើទៅមេឃុំ-ចៅសង្កាត់ឲ្យរឹតបន្តឹងការចេញលិខិតបញ្ជាក់នៅលីវឲ្យនារីវ័យក្មេង គោលបំណងយកទៅបំពេញបែបបទ ចុះលិខិតអាពាហ៍ពិពាហ៍ជាមួយបុរសជនជាតិចិន នៅប្រទេសចិន ដើម្បីចូលរួមការងារបង្ការ-ទប់ស្កាត់ និងរកឃើញមេខ្យល់ជួញដូរមនុស្ស
+ស្នើឲ្យមានកិច្ចសហប្រតិបត្តិការ ជំនួយឲ្យគ្នាទៅវិញទៅមកផ្នែកច្បាប់ ជាមួយប្រទេសចិន និងវៀតណាម ដើម្បីបំពេញឲ្យនីតិវិធី និងស្រាវជ្រាវបង្ក្រាបដល់ឫសគល់។
+ស្នើសុំឲ្យភាគីចិនរឹតបន្តឹងការចុះលិខិតអាពាហ៍ពិពាហ៍ឲ្យនារីខ្មែរ នៅប្រទេសចិន ដោយសួរនារីខ្មែរដោយឡែក ដើម្បីបញ្ជាក់ឲ្យច្បាស់ពីការសម្រេចចិត្ត ប្រសិនបើរកឃើញភាពមិនប្រក្រតី ត្រូវបញ្ជូនសាមីខ្លួនឲ្យស្ថានទូតខ្មែរ ដើម្បីចាត់វិធានការបន្ត។

+ស្នើឲ្យអាជ្ញាធរចិនរឹតបន្តឹងការស្នាក់នៅខុសច្បាប់របស់នារីខ្មែរ និងរកឲ្យឃើញមេខ្យល់នាំទៅចិន ចាត់ការតាមផ្លូវច្បាប់។

+ស្នើសុំឲ្យបុរសជនជាតិចិន ដែលមានបំណងចង់បានប្រពន្ធខ្មែរ គួរមកស្នើសុំរៀបការ ដោយអនុវត្ត តាមអនុក្រឹត្យ១៨៣អ.ន.ក្រ.

+ស្នើសុំទៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ឲ្យរឹងបន្តឹង ការចេញទៅប្រទេសចិន របស់នារីខ្មែរវ័យក្មេង ដោយសម្ភាសន៍បឋមរកឲ្យឃើញភាពមិនប្រក្រតី នៃការយកលេសធ្វើទេសចរណ៍ តាមការណែនាំ របស់មេខ្យល់។

ថ្ងៃព្រហស្បតិ៍ ០៥កើត ខែពិសាខ ឆ្នាំច សំរិទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៨
**នាយការិយាល័យ**

វរសេនីយ៍ឯក **គីម_ចិន្តា**

បានឃើញ និង ឯកភាព
ថ្ងៃព្រហស្បតិ៍ ០៥កើត ខែពិសាខ ឆ្នាំច សំរិទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៨
**អនុប្រធាននាយកដ្ឋាន**

ឧត្តមសេនីយ៍ទោ **ស្វ_វ៉ាន់ឌី**